5127
24/8

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខៈ ៥២៥៥ កសក.បុ

រាជធានីភ្នំពេញ,ថ្ងៃទី 14 ខែ 11 ឆ្នាំ ២០០១

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ជំរាបមក

**- ឯកឧត្តម លោកប្រធានគ្រប់អង្គភាព ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**- លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទគ្រប់ខេត្ត/ក្រុង**

**កម្មវត្ថុ :** អំពីការរៀបចំបែបបទស្នើសុំគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា ជូនមន្ត្រីកសិកម្ម ។

ដើម្បីជាការលើកទឹកចិត្ត ព្រមទាំងចារឹកទុកក្នុងប្រវត្តិក្នុងកិច្ចការការពារ និងកសាងប្រទេសជាតិ និងដើម្បីអនុវត្តតាមអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ ២០០០ និងសារាចរណែនាំលេខ ០១ សរណន ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០០១ របស់រាជរដ្ឋាភិបាល សំរាប់ផ្តល់ជាកិត្តិយសដល់មន្ត្រីកសិកម្ម ដែលមានគុណបំណាច់ និងមានស្នាដៃដ៏ខ្ពង់ខ្ពស់ ក្នុងការបំពេញសកម្មភាពការងារ ឬក្នុងមុខវិជ្ជាជីវៈរបស់ខ្លួន ក្រសួងសូមធ្វើការណែនាំអំពីការរៀបចំបែបបទ ស្នើសុំគ្រឿងឥស្សរិយយសគ្រប់ប្រភេទ មានខ្លឹមសារដូចខាងក្រោម ÷

១-គ្រប់អង្គភាពចំណុះក្រសួង និងគ្រប់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបង្កើតអោយមានគណៈកម្មការពិនិត្យលក្ខណៈសម្បត្តិវរជន មន្ត្រីកសិកម្ម ដែលត្រូវស្នើសុំគ្រឿងឥស្សរិយយសនៅថ្នាក់របស់ខ្លួនមួយដែលមានសមាសភាពចំនួន ០៥ រូបគឺ ប្រធាន ឬអនុប្រធានអង្គភាពនោះ ជាប្រធានគណៈកម្មការ ប្រធានការិយាល័យរដ្ឋបាល-បុគ្គលិក ជាអនុប្រធានគណៈកម្មការ ហើយនិងប្រធានការិយាល័យសំខាន់ៗក្រោមឱវាទជាសមាជិក ។

២-គណៈកម្មការនេះ មានភារកិច្ចដូចខាងក្រោម ÷

- ពិនិត្យលក្ខណៈសម្បត្តិរបស់វរជន មន្ត្រីកសិកម្មក្រោមឱវាទ ដែលមានស្នាដៃ និងគុណបំណាច់ដ៏ខ្ពង់ខ្ពស់ក្នុងការងារ នៅក្នុងបុព្វហេតុស្ថារ និងអភិវឌ្ឍន៍ប្រទេសជាតិ ដើម្បីជ្រើសរើសជាបេក្ខជន ស្នើសុំផ្តល់គ្រឿងឥស្សរិយយសទៅតាមប្រភេទ និងទៅតាមទំហំ កេរ្តិ៍ ស្នាដៃ ។
- ពិនិត្យវាយតំលៃស្នាដៃរបស់អង្គភាព ឬរបស់បុគ្គល រួចដាក់ជូនប្រធានអង្គភាព ពិនិត្យសំរេច ហើយបញ្ជូនមកឯកឧត្តមរដ្ឋមន្ត្រី ដើម្បីសុំផ្តល់គ្រឿងឥស្សរិយយស ។
- អនុវត្តនីតិវិធី ទំរង់បែបបទ និងអំពីបរិមាណវរជន មន្ត្រីកសិកម្ម ដែលត្រូវធ្វើសំណើសុំគ្រឿងឥស្សរិយយស ស្របទៅនឹងបណ្តាគោលការណ៍ដែលបានណែនាំ និងបានកំណត់រួចហើយ ។

៣-វរជន មន្ត្រីកសិកម្មសំរាប់ជ្រើសរើសជាបេក្ខជន និងធ្វើសំណើសុំគ្រឿងឥស្សរិយយស ត្រូវមានលក្ខណៈសម្បត្តិធំៗជាចាំបាច់ ៥ ចំណុច ដូចខាងក្រោម ÷

ក-សីលធម៌រស់នៅស្អាតស្អំ មិនប្រព្រឹត្តអំពើពុករលួយ និងសកម្មភាពផ្ទុយនឹងច្បាប់រដ្ឋ ។

ខ-គំនិតផ្តួចផ្តើម និងមនសិការវិជ្ជាជីវៈខ្ពស់ សកម្មការងារ ឧស្សាហ៍ព្យាយាម ច្នៃប្រឌិត ទទួលខុសត្រូវ និងមានលទ្ធផលល្អប្រសើរ ដែលមហាជនគាំទ្រ និងកោតសសើរអំពីស្នាដៃ ។

គ-ការដឹកនាំ និងគ្រប់គ្រងមានប្រសិទ្ធិភាព ។

ឃ-ស្មារតីស្នេហាជាតិ គិតគូរដល់ផលប្រយោជន៍ជាតិ និងកិត្តិយសរបស់ក្រសួង ។

ង-សាមគ្គីភាព ទំនាក់ទំនងល្អ ជាមួយមហាជន ។

៤-ចំនួនវរជន មន្ត្រីកសិកម្ម ជាបេក្ខជនប្រចាំឆ្នាំ សំរាប់ស្នើសុំគ្រឿងឥស្សរិយយស ត្រូវគិតតែមន្ត្រីក្នុងក្របខ័ណ្ឌមុខងារសាធារណៈប៉ុណ្ណោះ ដែលត្រូវកំណត់យកមិនត្រូវលើសពី ១០% នៃចំនួនក្របខ័ណ្ឌសរុបរបស់អង្គភាព ហើយដែលចាំបាច់ត្រូវគិតទៅតាមទំហំស្នាដៃ និងត្រូវផ្លាស់វេនគ្នារយៈពេល ២ ឆ្នាំ ម្តង ។ ក្នុងចំនួនសមាមាត្រ ១០ % នេះ ត្រូវជ្រើសរើសក្នុងក្របខ័ណ្ឌមន្ត្រីកសិកម្មមានថ្នាក់ស្មើមន្ត្រីជាន់ខ្ពស់ ( ថ្នាក់អនុប្រធាននាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែលឡើងទៅ ) ០២ % មន្ត្រីក្របខ័ណ្ឌមានថ្នាក់ស្មើមន្ត្រីក្រមការ ( ថ្នាក់ការិយាល័យ និងថ្នាក់ប្រហាក់ប្រហែល ) ០៣ % និងមន្ត្រីរាជការ ០៥ % ។

៥-ជារៀងរាល់ឆ្នាំ ប្រធានអង្គភាពនីមួយៗ ត្រូវបញ្ជូនសំណើ និងបញ្ជីឈ្មោះបេក្ខជនដែលត្រូវស្នើសុំផ្តល់គ្រឿងឥស្សរិយយសនោះ អោយបានមកដល់ក្រសួង យ៉ាងយូរបំផុតត្រឹមថ្ងៃទី ៣០ ខែកក្កដា ដើម្បីក្រសួង មានលទ្ធភាពធ្វើការពិនិត្យវាយតំលៃ សំរេច និងលើកសំណើទៅទីស្តីការគណៈរដ្ឋមន្ត្រី អោយបានទាន់តាមកាល កំណត់ របស់រាជរដ្ឋាភិបាល ទើបអាចទទួលគ្រឿងឥស្សរិយយសទាំងនោះ ជូនមន្ត្រីរាជការ នាឱកាសដំណាច់ឆ្នាំនីមួយៗបាន ។

ក្នុងជំហានដំបូង សំរាប់ឆ្នាំ ២០០១ នេះ ការបញ្ជូនសំណើ និងបញ្ជីឈ្មោះវរជន មន្ត្រីកសិកម្ម ដែលត្រូវស្នើសុំគ្រឿងឥស្សរិយយសនេះ ត្រូវអោយមកដល់ក្រសួង យ៉ាងយឺតបំផុត ត្រឹមថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០១ ជាកំណត់ ដោយភ្ជាប់មកជាមួយ :

* កំណត់ហេតុវាយតំលៃរបស់គណៈកម្មការ ។
* បញ្ជីរាយនាមវរជន និងមន្ត្រីរាជការដែលបានទទួលគ្រឿងឥស្សរិយយសកន្លងមក តាមគំរូតារាងភ្ជាប់ជាមួយនេះ ។

សំណើរបស់អង្គភាពណា ដែលបញ្ជូនមកដល់ក្រសួង ក្រោយកាលបរិច្ឆេទ ដូចដែលបានកំណត់ខាងលើនេះ ក្រសួងនឹងមិនទទួលពិនិត្យឡើយ ហើយចាត់ទុកដូចជាប្រធានអង្គភាពនោះ ពុំបានធ្វើសំណើដែរ ។

៦-នៅមូលដ្ឋានថ្នាក់ខេត្ត/ក្រុង បញ្ជីបេក្ខជន វរជន មន្ត្រីកសិកម្ម ដែលត្រូវស្នើសុំផ្តល់គ្រឿងឥស្សរិយយសនោះ ត្រូវមានការឯកភាពគ្នា ពីអាជ្ញាធរមូលដ្ឋាន មុននឹងបញ្ជូនមកក្រសួង ។

អាស្រ័យហេតុនេះ ពេលទទួលបានលិខិតណែនាំនេះ ខ្ញុំសូមឯកឧត្តម លោកប្រធានគ្រប់អង្គភាពចំណុះ ត្រូវខិតខំយកចិត្តទុកដាក់ ចាត់ការអនុវត្តតាមខ្លឹមសារខាងលើនេះ និងផ្អែកតាមស្មារតី នៃអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ ២០០០ និងសារាចរណែនាំលេខ ០១ សរណន ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០០១ របស់រាជរដ្ឋាភិបាល ដោយស្មារតីទទួលខុសត្រូវ ធ្វើទាន់ពេលវេលា មានភាពត្រឹមត្រូវ យុត្តិធម៌ និងអោយមានប្រសិទ្ធភាពខ្ពស់ ។ ៚

រដ្ឋមន្ត្រី

ចាន់-សារុន

**ចម្លងជូន**
- ទីស្តីការ គណៈរដ្ឋមន្ត្រី
- ថ្នាក់ដឹកនាំក្រសួងគ្រប់រូប
- គណៈកម្មការពិនិត្យលក្ខណៈសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយសរបស់ក្រសួង "**ដើម្បីជូនជ្រាប**"
- ឯកសារ-កាលប្បវត្តិ